00896330

E256/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 04 / 2013
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៣
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE

## ១. សេចក្តីផ្តើម

1. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទ នួន ជា មានកាយសម្បទា និងបញ្ញាស្មារតីចូលរួមក្នុងសវនាការបាន[1]។ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ស្ថានភាពសុខភាពជនជាប់ចោទមានសភាពទន់ខ្សោយ ដោយសារជំងឺប្រចាំកាយរបស់គាត់ ហើយបានបង្គាប់ឱ្យសាស្ត្រាចារ្យ A. John CAMPBELL ("អ្នកជំនាញផ្នែកជំងឺមនុស្សចាស់") និង វេជ្ជបណ្ឌិត Seena FAZEL (ហៅជារួម "អ្នកជំនាញវេជ្ជសាស្ត្រ")[2] វាយតម្លៃជនជាប់ចោទឡើងវិញ។ ក្រោយពីអង្គជំនុំជម្រះបានតែងតាំងអ្នកជំនាញរួចមក ជនជាប់ចោទ នួន ជា ដែលមានវ័យ ៨៦ ឆ្នាំ ត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យចំនួនពីរលើក[3] ។ បន្ទាប់ពីបានចាកចេញពីមន្ទីរពេទ្យនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ របាយការណ៍វេជ្ជសាស្ត្របានបញ្ជាក់ថា សុខភាពរបស់គាត់មានសភាពនឹងនរ[4]។ បន្ទាប់ពីបានទទួលរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ និងបន្ទាប់ពីបើកសវនាការដែលផ្តល់លទ្ធភាពឱ្យអ្នកជំនាញផ្តល់សក្ខីកម្ម

[1] សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារលេខ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើកទីមួយលើសម្បទារបស់ នួន ជា") កថាខណ្ឌ ៣៥។

[2] "ការតែងតាំងជាថ្មីនូវអ្នកជំនាញដើម្បីពិនិត្យឡើងវិញអំពីសុខភាព និងសម្បទារបស់ អៀង សារី និង នួន ជា ក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣" ឯកសារលេខ E256 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។ ទោះបីជាវេជ្ជបណ្ឌិត ហួត លីណា ត្រូវបានតែងតាំងពីដំបូងឱ្យធ្វើការពិនិត្យក៏ដោយ ក៏លោកវេជ្ជបណ្ឌិតពុំអាចមានលទ្ធភាពចូលរួមក្នុងការពិនិត្យនេះដែរ។ *សូមមើលផងដែរ* "ការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញសម្រាប់ដើមឆ្នាំ ២០១៣" ឯកសារលេខ E236/4 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ ("ការកំណត់កាលបរិច្ឆេទឡើងវិញលើការពិនិត្យវាយតម្លៃសម្រាប់អាទិត្យថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៣")។

[3] ការពិនិត្យសុខភាព នួន ជា E1/1603 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣, លិខិតមកពីមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតផ្ញើជូនប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងរបាយការណ៍សុខភាពរបស់ នួន ជា ឯកសារលេខ E10/116/4 ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[4] លិខិតមកពីមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតផ្ញើជូនប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងរបាយការណ៍សុខភាពរបស់ នួន ជា ឯកសារលេខ E10/119/1 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។ Rapport médical hebdomadaire de NUON Chea ឯកសារលេខ E10/120 ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣។ Rapport médical hebdomadaire de NUON Chea ឯកសារលេខ E10/121 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។ Rapport médical hebdomadaire de NUON Chea ឯកសារលេខ E10/122 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣។ Rapport médical hebdomadaire de NUON Chea ឯកសារលេខ E10/123 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣។

00896332



និងភាគីធ្វើសេចក្តីសន្និដ្ឋានរួចមក អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទនៅក្នុងការចូលរួមសវនាការ[5]។

## ២. ប្រវត្តិនីតិវិធី

2. ក្រោយពេលចាប់ខ្លួនជនជាប់ចោទនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៧[6] សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យធ្វើការពិនិត្យសុខភាពពេញលេញមួយ ដែលនៅពេលនោះ ជនជាប់ចោទបានបង្ហាញថាមានជំងឺបេះដូង ជំងឺហើមក្រពេញប្រូស្តាតក្នុងកម្រិតមធ្យម ជំងឺសន្លាក់ឆ្អឹងកងចង្កេះ និងមានតម្រងនោមតែមួយពីកំណើត[7]។ នៅក្នុងខែ តុលា ឆ្នាំ ២០០៧ គ្រូពេទ្យបេះដូងចំនួនបីរូបបានពិនិត្យជនជាប់ចោទ និងបានធ្វើរោគវិនិច្ឆ័យឃើញថា គាត់មានជំងឺសម្ពាធឈាមខ្ពស់ដោយពុំអាចដឹងមុនបាន ហើយមានជំងឺចុះខ្សោយតម្រងនោមក្នុងកម្រិតមធ្យម[8]។ គ្រូពេទ្យបេះដូងក៏បានរកឃើញផងដែរថា ជនជាប់ចោទមានការចុះខ្សោយការចងចាំក្នុងកម្រិតមធ្យម ប៉ុន្តែ ការចងចាំរឿងរ៉ាវកើតឡើងយូរៗមកហើយនៅមានសភាពដដែល ហើយសមត្ថភាពបញ្ញាស្មារតីរបស់គាត់គ្រប់គ្រាន់សមទៅតាមវ័យរបស់គាត់[9]។

3. នៅក្នុងឆ្នាំ ២០០៨ និងឆ្នាំ ២០០៩ គ្រូពេទ្យបេះដូងចំនួនពីររូបបានពិនិត្យជនជាប់ចោទសារជាថ្មី និងបានរកឃើញថា ស្ថានភាពសុខភាពរបស់គាត់ពុំមានអ្វីប្រែប្រួលឡើយ[10]។ គ្រូពេទ្យក៏បាន

---

[5] របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញសម្រាប់លោក នួន ជា ដែលរៀបចំឡើងតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង (E256) ឯកសារលេខ E256/4 ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ("របាយការណ៍របស់អ្នកជំនាញចុះខែ មីនា ឆ្នាំ ២០១៣")។

[6] កំណត់ហេតុនាំខ្លួនជនសង្ស័យ នួន ជា ឯកសារលេខ C7 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧។

[7] អនុស្សរណៈផ្ទៃក្នុងស្តីពីសុខភាពរបស់ នួន ជា (ក.ស.ច.ស) ឯកសារលេខ A38 ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧។

[8] របាយការណ៍វេជ្ជសាស្ត្រស្តីពី នួន ជា ពីមន្ទីរពេទ្យ BNH នៃប្រទេសថៃ ឯកសារលេខ D24/II ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៧។ របាយការណ៍គ្រូពេទ្យកម្ពុជា ឯកសារលេខ D24/IV ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧។ របាយការណ៍គ្រូពេទ្យបារាំង ឯកសារលេខ D24/VII ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧។

[9] របាយការណ៍វេជ្ជសាស្ត្រស្តីពី នួន ជា ពីមន្ទីរពេទ្យ BNH នៃប្រទេសថៃ ឯកសារលេខ D24/II ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៧។ របាយការណ៍គ្រូពេទ្យកម្ពុជា ឯកសារលេខ D24/IV ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧។របាយការណ៍គ្រូពេទ្យកម្ពុជា ឯកសារលេខ D24/IV ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧។ របាយការណ៍គ្រូពេទ្យបារាំង ឯកសារលេខ D24/VII ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧។

[10] របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញស្តីពី នួន ជា ឯកសារលេខ B24/IX ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៨ របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញស្តីពី នួន ជា ឯកសារលេខ B14/1 ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ ទំព័រ ២ របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញស្តីពី នួន ជា ឯកសារលេខ B27/1 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩។

សន្និដ្ឋានផងដែរថា ជនជាប់ចោទពុំបានបង្ហាញរោគសញ្ញានៃការចុះខ្សោយសតិបញ្ញា រោគសញ្ញាវង្វេងម៉ោង ពេល ឬ ទីកន្លែង ឬ មានរោគសញ្ញាវិកលចរិតនោះទេ[11]។ នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានតែងតាំងគ្រូពេទ្យផ្នែកវិកលចរិតចំនួនពីររូបឱ្យធ្វើការវាយតម្លៃជនជាប់ចោទ និងកំណត់ថាតើជនជាប់ចោទមានសម្បទានៅក្នុងការចូលរួមសវនាការបាន ឬមិនបាន[12]។ ក៏ប៉ុន្តែ ក្រុមមេធាវីការពារក្តី នួន ជា បានតវ៉ាលើមូលដ្ឋានសំអាងនៅក្នុងដីកាសម្រេចតែងតាំង ឆ្នាំ ២០០៩ ហើយបានផ្តល់ការណែនាំដល់ជនជាប់ចោទកុំឱ្យសហការជាមួយនឹងការវាយតម្លៃលើជំងឺវិកលចរិត[13]។ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ និងខែ កក្កដា ឆ្នាំ ២០១០ គ្រូពេទ្យបេះដូងបានពិនិត្យជនជាប់ចោទឡើងវិញ ដោយបានតម្កល់ការរកឃើញរបស់ខ្លួនមុនៗ និងបានរាយការណ៍ថា សុខភាពរបស់ជនជាប់ចោទមានសភាពនឹងនរ[14]។

4. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[15]។ ចាប់តាំងពីដើមដំបូងនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២ ជនជាប់ចោទលើកលែងតែករណីខ្លះប៉ុណ្ណោះ បានចូលរួមនៅក្នុងវគ្គសវនាការជំនុំជម្រះដោយផ្ទាល់នាពេលព្រឹកក្នុងបន្ទប់សវនាការ និងបានចូលរួមនៅក្នុងវគ្គសវនាការជំនុំជម្រះក្នុងពេលរសៀលពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការតាមរយៈមធ្យោបាយសោតទស្សន៍[16]។ ជនជាប់ចោទតាមរយៈមេធាវីរបស់គាត់ បានត្អូញថា គាត់មានរោគសញ្ញាមួយចំនួនដែលមិនអាចឱ្យគាត់តាមដានវគ្គសវនាការជំនុំជម្រះក្នុងពេលរសៀលបាន។ ក៏ប៉ុន្តែ ជនជាប់ចោទបានបោះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងវគ្គសវនាការជំនុំជម្រះ ដោយបន្តចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោម

---

[11] ដូចជើងទំព័រខាងលើ។

[12] ដីកាសម្រេចចាត់តាំងអ្នកជំនាញ ឯកសារលេខ B35 ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩។

[13] លិខិតរបស់មេធាវីការពារក្តី នួន ជា ស្តីពីដីកាសម្រេចចាត់តាំងអ្នកជំនាញ ឯកសារលេខ B35/2 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩។

[14] របាយការណ៍កោសល្យវិច័យរបស់ នួន ជា ឯកសារលេខ B41/1 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩។ របាយការណ៍កោសល្យវិច័យរបស់ នួន ជា ឯកសារលេខ B48/1 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១០។

[15] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, D427/2/12, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

[16] សូមមើលវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង។

សាលសវនាការ[17]។ រោគសញ្ញាដែលជនជាប់ចោទបានរាយការណ៍នោះរួមមាន ឈឺក្បាល ឈឺចង្កេះ អស់កម្លាំង និងពុំអាចផ្ចង់អារម្មណ៍បាន[18]។

5. នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីបានដាក់ពាក្យសុំឱ្យតែងតាំងអ្នកជំនាញម្នាក់ដើម្បីកំណត់ពីបញ្ហាកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទនៅក្នុងការចូលរួមសវនាការ[19]។ អង្គជំនុំជម្រះបានតែងតាំងអ្នកជំនាញផ្នែកជំងឺមនុស្សចាស់ ដែលបានរកឃើញនៅក្នុងរបាយការណ៍ចុះ ខែ មិថុនា ឆ្នាំ ២០១១ ដូចតទៅ៖

> [ជនជាប់ចោទ] បង្ហាញនូវសញ្ញានៃជំងឺដាច់សរសៃឈាម[១៩៩៥]ដែលមាននៅសេសសល់តិចតួច។ មុខងារនៃដំណើរការខួរក្បាលមានសភាពល្អ។ ខ្ញុំមិនឃើញមានភស្តុតាងបង្ហាញអំពីការអន់ថយនៃដំណើរការខួរក្បាល ដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់លទ្ធភាពរបស់ នួន ជា នៅក្នុងការយល់ដឹងអំពីកិច្ចដំណើរការនីតិវិធី ការណែនាំមេធាវី ការយល់អំពីសំណួរនានា និងបទចោទទាំងឡាយដែលដាក់បន្ទុកមកលើគាត់ ការឆ្លើយតបយ៉ាងសមស្រប និងការផ្តោតការយកចិត្តទុកដាក់នៅក្នុងពេលសវនាការឡើយ[20]។

6. អ្នកជំនាញផ្នែកជំងឺមនុស្សចាស់យល់ឃើញថា ជនជាប់ចោទមានសមត្ថភាព ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការបាន ហើយពិចារណាឃើញថា បន្ទប់សវនាការ និងបន្ទប់ឃុំខ្លួន ស្ថិតខាងក្រោមសាលសវនាការមានលក្ខណៈសមស្របទៅតាមតម្រូវការរបស់ជនជាប់ចោទ។ ក៏ប៉ុន្តែ អ្នកជំនាញរូបនេះបានផ្តល់អនុសាសន៍ឱ្យធ្វើការវាយតម្លៃឡើងវិញនៅមុនពេលចាប់ផ្តើមការជំនុំជម្រះ[21]។ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ក្រោយពីបានធ្វើការវាយតម្លៃឡើងវិញតាមការអញ្ជើញរបស់អង្គជំនុំជម្រះ អ្នកជំនាញបានសន្និដ្ឋានថា មុខងារសម្បទាផ្លូវកាយ និងខួរក្បាលរបស់ជនជាប់ចោទគ្មានការប្រែប្រួលអ្វីគួរឱ្យកត់សម្គាល់នោះទេ ចាប់តាំងពីពេលដែលអ្នកជំនាញធ្វើការវាយតម្លៃលើកដំបូង។ ជនជាប់ចោទទទួលបានពិន្ទុ ៣០ លើ ៣០

---

[17] *សូមមើល* លិខិតរបស់ នួន ជា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូងស្តីពី "ការលះបង់សិទ្ធិចូលរួមក្នុងសវនាការ" E1/122.4, ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២។ លិខិតរបស់ នួន ជា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូងស្តីពី "ការលះបង់សិទ្ធិចូលរួមក្នុងសវនាការ" E1/153.5 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២។

[18] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៥២។ ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៥៩។ ប្រតិចារឹក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៥៨។

[19] សំណើជាបន្ទាន់សុំចាត់តាំងអ្នកជំនាញផ្នែកសម្បទា, E30, ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១១។

[20] របាយការណ៍រៀបចំឡើងជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង - ដីកាលេខ E62/3 ឯកសារ E62/3/4 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ១៥។

[21] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៨-២៩។

នៅក្នុងការធ្វើតេស្ត MMSE (ដែលជាតេស្តលើការចងចាំធម្មតា និងតេស្តលើសតិបញ្ញា)។ ក៏ប៉ុន្តែ អ្នកជំនាញកត់សម្គាល់ឃើញជនជាប់ចោទមាន "បញ្ហាសុខភាពជាច្រើនដែលពិតជា ប៉ះពាល់ ដល់លទ្ធភាពក្នុងការអង្គុយ និងការផ្តង់ស្មារតីដើម្បីសញ្ជឹងគិតអ្វីមួយក្នុងរយៈពេលយូរ [...]។ រយៈពេលដែលគាត់អាចផ្តង់ស្មារតីដើម្បីសញ្ជឹងគិតនេះពិត ជាអាចប្រែប្រួល និងអាចឆាប់ ជាងមួយម៉ោងកន្លះនេះផង។ ប្រការនេះតម្រូវឱ្យគេយកទៅ ពិចារណានៅពេលសម្រេចអំពី រយៈពេលសម្រាប់ធ្វើសវនាការ"[22]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់រយៈពេលសម្រាប់ ធ្វើសវនាការចាប់ពីម៉ោង ៩ ព្រឹក រហូតដល់ម៉ោង ៤ ល្ងាច រៀងរាល់ថ្ងៃចន្ទដល់ថ្ងៃព្រហស្បត្តិ៍ ដោយវគ្គនីមួយៗមិនលើសពីរយៈពេលមួយម៉ោង និងសាមសិបនាទី[23]។

7. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា គ្មាន ភស្តុតាងណាមួយបង្ហាញអំពីការចុះខ្សោយខ្លាំងលើការចងចាំរយៈពេលវែង និងរយៈពេលខ្លី របស់ជនជាប់ចោទនោះទេ។ ផ្អែកតាមសក្ខីកម្ម និងរបាយការណ៍របស់អ្នកជំនាញ និងយោង តាមឯកសារសុខភាពពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា គ្មាន ភស្តុតាងបង្ហាញអំពីការចុះខ្សោយលើមុខងារសម្បទារាងកាយ ឬខួរក្បាលរបស់ជនជាប់ចោទ ដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់គាត់នៅក្នុងការចូលរួមសវនាការឡើយ[24]។

8. របាយការណ៍សុខភាពរបស់ជនជាប់ចោទប្រចាំសប្តាហ៍ចាប់តាំងពីខែ មករា ឆ្នាំ ២០១២ មក បានបញ្ជាក់ជាទូទៅថា ស្ថានភាពរបស់ជនជាប់ចោទមានសភាពនឹងនរ (*état conservé* or *stationnaire*) សតិស្មារតីដឹងឮ និងសតិស្មារតីយកចិត្តទុកដាក់របស់ជនជាប់ចោទមានសភាព ធម្មតា ទោះបីជាពេលខ្លះរបាយការណ៍ទាំងនេះលើកឡើងថា ជនជាប់ចោទមានបញ្ហាលើការ ទប់លំនឹងខ្លួននៅពេលដើរក៏ដោយ[25]។ នៅក្នុងពេលមួយចំនួនក្នុងអំឡុងខែ វិច្ឆិកា និងខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះបានទទួលរបាយការណ៍សុខភាពនៅមុនពេលចាប់ផ្តើមកិច្ចដំណើរការ

---

[22] របាយការណ៍វាយតម្លៃបន្ថែមពាក់ព័ន្ធនឹងលោក នួន ជា អនុលោមតាមដីកាចាត់តាំងអ្នកជំនាញ E62/3 របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១។

[23] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[24] សេចក្តីសម្រេចលើកទីមួយលើសម្បទារបស់ នួន ជា។

[25] *សូមមើល* របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា, E10/51, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា, E10/88, ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២។

នីតិវិធីជំនុំជម្រះដែលបញ្ជាក់ថា ជនជាប់ចោទមានអាការៈវិលមុខ អស់កម្លាំង និងសម្ពាធឈាមឡើង[26]។ ក៏ប៉ុន្តែ គ្រូពេទ្យព្យាបាលទទួលបន្ទុកតាមដានសុខភាពរបស់ជនជាប់ចោទបានពិចារណាឃើញថា ជនជាប់ចោទអាចមានលទ្ធភាពចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការបាន[27]។

9. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ ជនជាប់ចោទបានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយគ្រូពេទ្យរកឃើញថាគាត់មានជំងឺរលាកទងសួតស្រួចស្រាល់ និង ខ្សោយកម្លាំងជើងទាំងពីរ[28]។ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ គាត់ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ ប៉ុន្តែ តម្រូវឲ្យសម្រាកពីរសប្តាហ៍ដើម្បីយកកម្លាំង[29]។ នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ជនជាប់ចោទត្រឡប់ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យម្តងទៀត ដោយសារការឡើងសម្ពាធឈាម និង ចេះតែងងុយដេក[30]។ របាយការណ៍សុខភាពក្រោយៗមកទៀត បញ្ជាក់ថា

[26] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ៣ (មានអាការៈវិលមុខ), ទំព័រ ៥៣-៥៦ (ដោយទទួលការត្រួតពិនិត្យវេជ្ជសាស្ត្រ ជនជាប់ចោទអស់កម្លាំងខ្លាំង), ទំព័រ ៥៨។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៦៦ (ជនជាប់ចោទភ្ញាក់ពីដំណេកដោយមានសម្ពាធឈាមឡើងខ្ពស់) ។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ២(មានសម្ពាធឈាមកើនឡើងខ្ពស់ ហើយមានអារម្មណ៍ថាទន់ខ្សោយកម្លាំង) ។

[27] របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា នៅចំពោះមុខកិច្ចដំណើរការនីតិវិធីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ E1/143.2 ចុះថ្ងៃទី ១២ ខែ វិច្ឆិការ ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា មុនពេលសវនាការនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ E1/144.3 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា នៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ E1/145.3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា នៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ E1/146.3 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា នៅចំពោះមុខកិច្ចដំណើរការនីតិវិធីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ E1/151.2 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា នៅចំពោះមុខកិច្ចដំណើរការនីតិវិធីថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ E1/155.3 ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២។

[28] របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E1/160.3, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/105 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣។

[29] ប័ណ្ណអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ– នួន ជា E10/116/1, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/116/2, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣។

[30] លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/116/4, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

ជនជាប់ចោទមានអាការៈក្អក និងខ្សោយកម្លាំងខ្លាំង[31]។កម្លាំងកំហែងរបស់គាត់បានវិលមករកភាពប្រសើរឡើងវិញបន្តិចម្តងៗ និង គាត់ត្រូវបានអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យ នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយគ្រូពេទ្យបញ្ជាក់ថា គាត់នឹងអាចមានលទ្ធភាពតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការបាន[32]។ របាយការណ៍សុខភាពចាប់តាំងពីពេលគាត់ចេញមន្ទីរពេទ្យបង្ហាញថាស្ថានភាពសុខភាពរបស់ជនជាប់ចោទមានសភាពនឹងនរ[33]។

## ៣. សេចក្តី

10. ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា លើកឡើងថា ជនជាប់ចោទនៅមានជំងឺជាច្រើនមុខ រួមមាន លើសឈាម រលាកប្រព័ន្ធផ្លូវដង្ហើម ឈឺចង្កេះ និង វិលមុខធីងធោង។ ក្រុមមេធាវីអះអាងថា មុខងារខាងសតិបញ្ញារបស់ជនជាប់ចោទក៏ចមចយដែរ។ ក្រុមមេធាវីលើកឡើងជំទាស់ថា ការនាំជនជាប់ចោទទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ គឺគ្មានន័យអ្វីទាំងអស់ ដ្បិតជនជាប់ចោទមិនមានលទ្ធភាពចូលរួមក្នុងសវនាការប្រកបដោយប្រសិទ្ធិភាពនោះទេ។ ហេតុដូច្នេះ ក្រុមមេធាវីស្នើសុំឱ្យអង្គជំនុំជម្រះ បង្គាប់ឱ្យអ្នកជំនាញពិនិត្យស្ថានភាព

[31] លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/116/5, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/117/1, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/118/1, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានស្តីទីនៃការិយាល័យរដ្ឋបាល អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/118/4, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/118/5, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/118/6, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[32] លិខិតពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជូនចំពោះប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អវតក អំពីរបាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/119/1, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[33] របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/120, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/121, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/122, ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៣។ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា E10/123, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣។

00896338



ស្មារតី និង រាងកាយរបស់ជនជាប់ចោទបន្ថែមទៀត និង បង្គាប់ឱ្យគ្រូពេទ្យព្យាបាលគាត់ រហូតគាត់ជះសះស្បើយ អាចចូលរួមក្នុងសវនាការបាន[34]។ ក្រុមមេធាវីស្នើជាជម្រើសមួយផងដែរ ដោយសុំអនុញ្ញាតឱ្យជនជាប់ចោទចូលរួមសវនាការពីមន្ទីរឃុំឃាំង តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារការនាំជនជាប់ចោទទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការរាល់ថ្ងៃ ធ្វើឱ្យជនជាប់ចោទអស់កម្លាំង[35]។

11. សហព្រះរាជអាជ្ញា លើកឡើងថាសំណើរបស់ក្រុមមេធាវីការពារក្តី ដែលស្នើសុំពិនិត្យសុខភាពជនជាប់ចោទបន្ថែមទៀត គឺមិនដូចអ្វីដែលអ្នកជំនាញរកឃើញក្នុងរបាយការណ៍ជំនាញនោះឡើយ។ សហព្រះអាជ្ញា ទទួលស្គាល់ថា សុខភាពរបស់ជនជាប់ចោទមានភាពទ្រុឌទ្រោម ប៉ុន្តែអះអាងថា ស្ថានភាពផ្លូវកាយរបស់គាត់នៅល្អ ឬ ស្ថិតក្នុងកម្រិតធម្មតាមួយ។ ការមានអាការៈវិលមុខ គឺបណ្តាលមកពីគាត់ពុំសូវធ្វើចលនាដោយខ្លួនគាត់។ សហព្រះរាជអាជ្ញាលើកឡើងបន្តទៀតថា ជនជាប់ចោទធ្វើបានពិន្ទុល្អ ពេលធ្វើតេស្តវាយតម្លៃស្មារតីរបស់គាត់ (MMSE) និងគាត់អាចឆ្លើយតបទៅនឹងសំណួរដែលអ្នកជំនាញសួរគាត់។ ដូច្នេះ សហព្រះរាជអាជ្ញា អះអាងថាជនជាប់ចោទពិតជាយល់អំពីលក្ខណៈនៃបទចោទ និង យល់អំពីកិច្ចដំណើរការនីតិវិធី និងគាត់មានសមត្ថភាពអាចចូលរួមការពារក្តីខ្លួនគាត់បាន[36]។

12. សហមេធាវីនាំមុខ ជំទាស់ទៅនឹងការស្នើសុំវាយតម្លៃសុខភាពបន្ថែមរបស់ក្រុមមេធាវីការពារក្តី។ ពួកគាត់លើកឡើងថា អ្នកជំនាញវេជ្ជសាស្ត្រទាំងនេះ គឺសុទ្ធតែមានគុណវុឌ្ឍិត្រឹមត្រូវ និងរបាយការណ៍ជំនាញទៀតសោត ក៏ជារបាយការណ៍លម្អិតពិតឥតលម្អៀង។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ដោយសារសុខភាពរបស់ជនជាប់ចោទមានសភាពនឹងនរ ពួកគាត់ស្នើបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដោយអនុញ្ញាតឱ្យជនជាប់ ចោទចូលរួមក្នុងសាលសវនាការផ្ទាល់ ឬពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ[37]។

---

[34] ប្រតិចារិក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រទី ៩៣-៩៤

[35] ចម្លើយតាមទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ឱ្យដាក់សារណាទាក់ទងនឹងវិសាលភាពនៃការពិនិត្យឡើងវិញនៃសម្បទា របស់ នួន ជា E256/2/1, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣។

[36] ប្រតិចារិក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រទី ៩៥-៩៧

[37] ប្រតិចារិក ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រទី ៩៧-១០២

## ៤. ច្បាប់ជាធរមាន

13. តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះសាលាដំបូង ឬរបស់ភាគី អង្គជំនុំជម្រះសាលាដំបូង[38] ត្រូវជឿជាក់ថា ជនជាប់ចោទពិតជាមានសមត្ថភាព"ចូលរួមសវនាការបានដោយមានអត្ថន័យ ដែលអាចឱ្យជនជាប់ចោទអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ក្នុងកម្រិតមួយ ដែលគាត់មានលទ្ធភាពចូលរួមឱ្យមានប្រសិទ្ធិភាពក្នុងការជំនុំជម្រះក្តីរបស់គាត់ និង យល់អំពី សារៈសំខាន់នៃកិច្ចដំណើរការនីតិវិធី"[39]។ អង្គជំនុំជម្រះសាលាដំបូង ត្រូវពិចារណារាល់ ឯកសារពាក់ព័ន្ធ និង កត្តាពាក់ព័ន្ធទាំងអស់ រួមទាំងសេចក្តីអង្កេតសមស្របរបស់ខ្លួនផង ដើម្បី សម្រេចក្នុងរឿងនេះ[40]។ អង្គជំនុំជម្រះ គប្បីពិចារណាបន្ថែមទៀតលើស្ថានភាពសុខភាពជាក់

---

[38] វិធាន ៣២ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ ព្រះរាជអាជ្ញា ទល់នឹង *Mladić*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-09-92-PT), ដីកាកំណត់កាលបរិច្ឆេទសវនាការ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌទី ១២-១៣ ("ទោះបីជាអង្គជំនុំជម្រះសាលាដំបូងស្តាប់កិច្ចការតុលាការ និង ការដាក់ឯកសារផ្សេងៗពីភាគីយ៉ាងខ្ជាប់ខ្ជួនយ៉ាងណាក្តី ក៏ អង្គជំនុំជម្រះមិនដែលបានទទួលសំណើសុំពីភាគីណាមួយសុំត្រួតពិនិត្យសុខភាពនៅឡើយទេ ដូច្នេះតាមគំនិតផ្តួចផ្តើមរបស់ ខ្លួន អង្គជំនុំជម្រះបានចេញបង្គាប់ឱ្យមានការត្រួតពិនិត្យសុខភាពពេញលេញមួយធ្វើឡើងដោយអ្នកជំនាញ" និង ដោយផ្អែល លើរបាយការណ៍ត្រួតពិនិត្យសុខភាពនេះ អង្គជំនុំជម្រះរកឃើញថា គ្មានចំណុចណាមួយបញ្ជាក់ថាជនជាប់ចោទ ពុំមិនអាច ចូលរួមសវនាការបាន ឬ សុខភាពរបស់គាត់តម្រូវឱ្យតុលាការកែប្រែកាលកាលបរិច្ឆេទសវនាការនោះឡើយ)។

[39] ការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺសំដៅទៅលើសមត្ថភាពក្នុងការអនុវត្តសិទ្ធិទាំងនេះ៖ ឧទាហរណ៍ សូមមើល វិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង (សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ សិទ្ធិការពារក្តីដោយ មេធាវី និង សិទ្ធិនៅស្ងៀមមិនឆ្លើយប)។ វិធាន ២២(៣) នៃវិធានផ្ទៃក្នុង (សិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវីដោយសេរី និង សម្ងាត់)។ វិធាន ៨១(១) (សិទ្ធិដាច់ខាតក្នុងការជំនុំជម្រះក្តីដោយមានវត្តមានរបស់ជនជាប់ចោទ) និង វិធាន ៨៥(១) (ការធានា"ការអនុវត្តសិទ្ធិការពារក្តីដោយសេរី")។ សូមមើលផងដែរ ព្រះរាជអាជ្ញា ទល់នឹង *Gbagbo*, អង្គបុរេជំនុំជម្រះនៃ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC-02/11-01/11), សេចក្តីសម្រេចលើសម្បទារបស់ Laurent Gbagbo ក្នុងការចូលរួមក្នុ ងសវនាការនៅចំពោះមុខតុលាការនេះ, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សេចក្តីសម្រេច *Gbagbo*"), កថាខណ្ឌទី ៤៣ ៤៩ ៥៦ (បដិសេធតុល្យភាពនៃបទដ្ឋានប្រហាក់ប្រហែល ដោយសម្រេចជ្រើសយកបទដ្ឋានដែលតម្រូវឱ្យអង្គជំនុំជម្រះ "ជឿជាក់") និង ៨៦ ("បញ្ហាគឺមិនស្ថិតនៅត្រង់ថាតើជនជាប់ចោទអាចមានវត្តមានដោយពេញលេញគ្រប់ពេល ទៅតាម កម្លាំងកាយ និងចិត្ត ដែលគាត់មានខ្ពស់ ឬ គ្រាន់បើជាងនេះពីមុនមកនោះទេ ប៉ុន្តែបញ្ហាគឺវាស្ថិតនៅត្រង់ថាតើក្នុងពេល បច្ចុប្បន្ននេះ គាត់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីឱ្យគាត់អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងមកលើរូបគាត់បាន ឬអត់") និង សេចក្តីសម្រេចស្តីពីសម្បទាចូលរួមក្នុងសវនាការរបស់លោកស្រី អៀង ធីរិទ្ធ, E138, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សេចក្តីសម្រេចស្តីពីសម្បទាចូលរួមសវនាការលើកទីដំបូងរបស់លោកស្រី អៀង ធីរិទ្ធ"), កថាខណ្ឌទី ២៧ (ដកស្រង់រឿងក្តីព្រះរាជអាជ្ញា ទល់នឹង *Strugar*, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-01-42-A), សាលដីកា ("សាលដីកាឧទ្ធរណ៍ *Strugar*"), ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌទី ៥៥)។

[40] សេចក្តីសម្រេចស្តីពីសម្បទាចូលរួមសវនាការលើកទីដំបូងរបស់លោកស្រី អៀង ធីរិទ្ធ កថាខណ្ឌទី ២៩។

លាក់ដែលមាន និង ផលប៉ះពាល់របស់វាទៅលើសម្បទារបស់ជនជាប់ចោទ[41]។ ការពិនិត្យរកមើលវិធានការជាក់ស្តែងមួយចំនួន ដើម្បីបន្ថយផលប៉ះពាល់អវិជ្ជមានពីការចុះខ្សោយខាងសុខភាពណាមួយគឺជាការចាំបាច់ផងដែរ[42]។

14. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY គូសបញ្ជាក់ថា គេមិនអាចរំពឹងទុកថា ជនជាប់ចោទដែលតំណាងដោយមេធាវីការពារក្តី អាចយល់ដឹងឯកសារពាក់ព័ន្ធនឹងរឿងក្តីគាត់បានដូចមេធាវីអាជីព និង មេធាវីមានបទពិសោធម្នាក់នោះទេ[43]។ សូម្បីតែមនុស្សដែលមានសម្បទាផ្លូវកាយ និង ផ្លូវចិត្តល្អយ៉ាងណាក្តី ប្រសិនបើគាត់ពុំមានការអប់រំផ្នែកច្បាប់ជ្រៅជ្រះ និង ជំនាញពាក់ព័ន្ធ នោះគាត់នឹងត្រូវការជំនួយផ្នែកច្បាប់យ៉ាងច្រើន ជាពិសេសក្នុងរឿងក្តីដែលមានភាពស្មុគស្មាញទាំងអង្គហេតុ និង អង្គច្បាប់ ដែលជំនុំជម្រះនៅចំពោះមុខសាលាក្តីអន្តរជាតិបែបនេះ។ ហេតុដូច្នេះ អ្វីដែលជាការតម្រូវសម្រាប់ឱ្យជនជាប់ចោទម្នាក់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលសវនាការបាន គឺទាល់តែគាត់មាន "សមត្ថភាពកម្រិតស្តង់ដារមួយ ដែលអាចធ្វើឱ្យគាត់ចូលរួមក្នុងសវនាការបានប្រកបដោយអត្ថន័យ និង គាត់ត្រូវមានមេធាវីតំណាងត្រឹមត្រូវ"[44]។ វត្តមាននៃមេធាវីការពារក្តី អាចជួយឱ្យជនជាប់ចោទ យល់ដឹងគ្រប់គ្រាន់អំពីភស្តុតាង និង លំហូរ និង តំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។ ទោះបីជាក្នុងករណីពិសេសណាមួយ វត្តមានមេធាវីការពារក្តី "អាចជួយប៉ះប៉ូវបន្ថែមនូវការខ្វះខាតនៃសមត្ថភាព ដែលខ្វះចន្លោះរបស់ជនជាប់ចោទ"យ៉ាងណាក្តី ក៏ការប្រើប្រាស់មេធាវីការពារក្តីឱ្យមានប្រយោជន៍គឺ "ទាល់តែជនជាប់ចោទមានសមត្ថភាពណែនាំមេធាវីនោះឱ្យបានសមស្រប

---

[41] សេចក្តីសម្រេច *Gbagbo* កថាខណ្ឌទី ៥១ (ដកស្រង់ ក្នុងចំណោមផ្នែកដទៃទៀត សាលដីកាឧទ្ធរណ៍របស់ *Strugar* កថាខណ្ឌទី ៦១ ៦៦។

[42] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ (អង្គជំនុំជម្រះតុលាការកំពូល), E138/1/7, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌទី ៣៧។ សេចក្តីសម្រេច *Gbagbo,* កថាខណ្ឌទី ៥១ ១០២ និង រឿងក្តី ព្រះរាជអាជ្ញា ទល់នឹង *Stanišić & Simatović,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-03-69-AR73.2), សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ស្តីពីសេចក្តីសម្រេចអំពីការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីទៅអនាគត ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ *Stanišić*"), កថាខណ្ឌទី ១៩-២០។

[43] សាលដីកាបណ្តឹងសាទុក្ខ *Strugar,* កថាខណ្ឌទី ៦០។

[44] សាលដីកាបណ្តឹងសាទុក្ខ *Strugar,* កថាខណ្ឌទី ៦០។

ទៅតាមគោលបំណងរបស់គាត់ផងដែរ”[45]។ ការអនុវត្តឱ្យមានប្រសិទ្ធិភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ទោះបីជនជាប់ចោទមានតំណាងដោយមេធាវីយ៉ាងណាក៏ដោយ ក៏“អាចមានការរារាំង ឬ បាត់បង់បានដែរ ប្រសិនបើជនជាប់ចោទមានបញ្ហាសុខភាពខាងស្មារតី និង រាងកាយ ជាពិសេសបញ្ហាគ្មានលទ្ធភាពក្នុងការយល់ដឹង *ឧទាហរណ៍* ការយល់ដឹងនេះរងផលប៉ះពាល់ដោយសារវិការៈផ្នែកស្មារតី ឬ រាងកាយ”[46]។ ហេតុដូច្នេះ ជនជាប់ចោទត្រូវតែមាន“សមត្ថភាពគ្រប់គ្រាន់ ដើម្បីបង្ហាញថាគាត់មានលទ្ធភាពការពារក្តីបានពិតប្រាកដមែន”[47]។

15. លើសពីនេះទៅទៀត ជនជាប់ចោទមានសិទ្ធិគ្រប់គ្រាន់ដើម្បីមានវត្តមានដោយផ្ទាល់នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីសវនាការ[48]។ វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបានបង្ហាញថា ការរំខានដល់កិច្ចដំណើរការនីតិវិធីអាចនាំឱ្យមានជម្រើសផ្សេងៗចំពោះវត្តមានដោយផ្ទាល់របស់ជនជាប់ចោទ ក្នុងករណីដែលជម្រើសទាំងនេះមានលក្ខណៈសមស្រប ចាំបាច់ និងមានសមាមាត្រ[49]។

16. នៅក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ជនជាប់ចោទអាចសម្រេចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយបាន។ អង្គជំនុំជម្រះក៏អាចបង្គាប់ឱ្យចូលរួមតាមរយៈឧបករណ៍សោតទស្សន៍ប្រសិនបើផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។ វិធាន ៨១(៥) នៃវិធានវិធានផ្ទៃក្នុង

---

[45] រឿងក្តីព្រះរាជអាជ្ញា ទល់នឹង *Strugar* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-04-42-T), សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ស្នើសុំពន្លត់កិច្ចដំណើរការនីតិវិធី ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ (“សេចក្តីសម្រេច *Strugar*”) កថាខណ្ឌទី ២២។

[46] សាលដីកាបណ្តឹងសាទុក្ខ *Strugar,* កថាខណ្ឌទី ២៣។

[47] សាលដីកាបណ្តឹងសាទុក្ខ *Strugar,* កថាខណ្ឌទី ២៤។

[48] វិធាន ៨១(១)។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងរបស់ *Stanišić* កថាខណ្ឌ ៦។ រឿងក្តីរវាង *Milošević* *តទល់នឹង រដ្ឋអាជ្ញា* អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-02-54-AR73.7)។ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងមេធាវីការពារក្តី ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ (“សាលដីកាលើបណ្តឹងរបស់ *Milošević*”) កថាខណ្ឌ ១៣។ រឿងក្តីរវាង *Zigiranyirazo* *តទល់នឹង រដ្ឋអាជ្ញា* អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-01-73-AR73) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦ (“សាលដីកាលើបណ្តឹងរបស់ *Zigiranyirazo*”) កថាខណ្ឌ ១៣។

[49] ការរំខានដល់កិច្ចដំណើរការនីតិវិធីមិនចាំបាច់ទាល់តែមានចេតនាដើម្បីអនុញ្ញាតឱ្យចាត់វិធានការទាំងនេះទេ។ *សូមមើល* វិធាន ៣៧(២) និងវិធាន ៨១(៥)។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងរបស់ *Stanišić* កថាខណ្ឌ ៦ និងកថាខណ្ឌ ១៩។ សាលដីកាលើបណ្តឹងរបស់ *Milošević* កថាខណ្ឌ ១៥។

ចែងដូចតទៅ៖

នៅពេលដែលមានមូលហេតុសុខភាព ឬ មូលហេតុធ្ងន់ធ្ងរដទៃទៀត ដែលធ្វើឱ្យជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែ រូបកាយ និងស្មារតីមានលក្ខណៈសមស្របអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបាន នោះអង្គជំនុំជម្រះអាចបន្តនីតិវិធីដោយមិនចាំបាច់មានវត្តមានរបស់ជនជាប់ចោទ ដោយមានការយល់ព្រមពីជនជាប់ចោទ ឬនៅពេលដែលអវត្តមានរបស់ជនជាប់ចោទឈានដល់កម្រិតមួយ ដែលបណ្តាលឱ្យមានការពន្យារពេលយ៉ាងយូរ ហើយនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវបែបនេះ នោះអង្គជំនុំជម្រះអាចបង្គាប់ថា ការចូលរួមរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវតែធ្វើឡើងតាមមធ្យោបាយសោតទស្សន៍សមស្រប។

## ៥. សម្អាងហេតុ

### ៥.១. របាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ

17. អ្នកជំនាញផ្នែកវេជ្ជសាស្ត្រមានគុណវុឌ្ឍិខ្ពស់ និងត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះជាច្រើនលើករួចមកហើយ[50]។ អ្នកជំនាញទាំងពីររូបបានធ្វើការវាយតម្លៃទៅលើសុខភាព ផ្លូវកាយ និងបញ្ហាស្មារតីរបស់ជនជាប់ចោទក្នុងរយៈពេលបីថ្ងៃ (គឺថ្ងៃទី ១៨, ១៩ និង ២០ ខែ មីនា ឆ្នាំ ២០១៣)[51]។ ខាងផ្នែករាងកាយ អ្នកជំនាញទាំងពីររូបបានរកឃើញថា ជនជាប់ចោទកាន់តែចុះខ្សោយទៅ[52]។ គាត់មានបញ្ហាឆ្អឹងខ្នងដែលចេះតែដុនដាបទៅជាយូរមកហើយ[53] និងមានអាការៈសាច់ដុំចុះខ្សោយ ដោយសារតែមានការធ្វើចលនារាងកាយក្នុងកម្រិតតិចតួចពេក[54]។ គាត់ទទួលបានការព្យាបាលជំងឺខ្សោយបេះដូង ប៉ុន្តែ ជំងឺសសៃឈាមបេះដូងរបស់គាត់ស្ថិតក្នុងស្ថានភាពមិនប្រែប្រួលទេ[55]។ គាត់ក៏មានការលំបាកក្នុងការអានអក្សរផងដែរ ដោយសារតែ

---

[50] របាយការណ៍សង្ខេបស្តីពីគុណវុឌ្ឍិរបស់អ្នកជំនាញ សាស្ត្រាចារ្យ Campbell ឯកសារ E62.1 ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១ និងសូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ។ ប្រវត្តិវិជ្ជាជីវៈរបស់អ្នកជំនាញ Seena Faze ឯកសារ E111.4។

[51] របាយការណ៍អ្នកជំនាញ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌទី ៣។

[52] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៨ និង កថាខណ្ឌ ១៥។

[53] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១១ កថាខណ្ឌ ១២ និងកថាខណ្ឌ ១៥។

[54] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩។

[55] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១៤។

មានជំងឺភ្នែកឡើងបាយទាំងសងខាង[56]។អ្នកជំនាញវេជ្ជសាស្ត្រយល់ឃើញថា ការត្អូញត្អែរពីបញ្ហាវិលមុខរបស់ជនជាប់ចោទ ជាចម្បង គឺណ្ដាលមកពីអារម្មណ៍មិនទុកចិត្តលើខ្លួនឯងនៅពេលឈរ ប៉ុន្តែ ក៏អាចបណ្តាលមកពីការមើលឃើញមិនច្បាស់នៅពេលអាន ដោយសារតែជំងឺភ្នែកឡើងបាយរបស់គាត់ផងដែរ[57]។ ទោះជាយ៉ាងនេះក្តី អ្នកជំនាញវេជ្ជសាស្ត្រទាំងពីរពិចារណាឃើញថា បញ្ហាទាំងនេះអាចធូរស្រាលមកវិញបាន[58]។ អ្នកជំនាញទាំងពីរក៏បានផ្តល់អនុសាសន៍ឱ្យចាត់វិធានការមួយចំនួនដែលអាចជួយធ្វើឱ្យរោគសញ្ញាដែលជនជាប់ចោទទទួលរងឈឺចាប់ មានសភាពធូរស្រាលមកវិញ[59]។ អ្នកជំនាញបានសន្និដ្ឋានថាបញ្ហាទាំងនេះមិនរារាំងដល់សមត្ថភាពរបស់ជនជាប់ចោទក្នុងការឆ្លើយតបទៅនឹងបទចោទ ឬ ការចូលរួមក្នុងសវនាការនោះទេ[60]។

18. ក្នុងពេលធ្វើការវាយតម្លៃអំពីសុខភាពនេះ អ្នកជំនាញវេជ្ជសាស្ត្រកត់សម្គាល់ឃើញថា ជនជាប់ចោទត្រូវបានទទួលឱ្យសម្រាកនៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺរលាកទងសួតស្រួចស្រាវ ប៉ុន្តែមិនបានរកឃើញថាមានរោគសញ្ញាណរលាកសួតទេ។ អ្នកជំនាញបានរាយការណ៍ថា ជំងឺរលាកទងសួតនឹងធ្វើឱ្យគាត់មានអារម្មណ៍អស់កម្លាំងមួយរយៈ ហើយក៏អាចឈានទៅដល់ស្ថានភាពរវើរវាយរយៈពេលពីរ ឬបីថ្ងៃ[61]។ មិនមានផលប៉ះពាល់ជាអចិន្ត្រៃយ៍ពីជំងឺរលាកទងសួតទេ ហើយការរវើរវាយនេះវាសះស្បើយទៅវិញដោយខ្លួនឯង។

19. ចំពោះសុខភាពផ្លូវចិត្តវិញ អ្នកជំនាញវេជ្ជសាស្ត្រទាំងពីរនេះកត់សម្គាល់ឃើញថា ជនជាប់-ចោទបានរាយការណ៍ថា ការចងចាំរបស់គាត់មានការចុះខ្សោយប៉ុន្មានឆ្នាំចុងក្រោយនេះ[62]។ ប៉ុន្តែ ជនជាប់ចោទទទួលបានពិន្ទុ ២៨ លើ ៣០ ពីការធ្វើតេស្តពិនិត្យស្ថានភាពផ្លូវចិត្តក្នុងកម្រិតអប្បរមា (MMSE) ក្នុងឱកាសពីរដាច់ដោយឡែកពីគ្នា[63]។ គាត់បានបង្ហាញពីការចងចាំរយៈពេលខ្លី និងរយៈពេលវែងដែលមិនមានផលប៉ះពាល់ បើទោះបីជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ

---

[56] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១១ និងកថាខណ្ឌ ៣៣។

[57] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១២ និងកថាខណ្ឌ ៤៩។

[58] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦ ដល់ ២១។

[59] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៦ កថាខណ្ឌ ៤៨ និងកថាខណ្ឌ ៤៩។

[60] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០។

[61] ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ១៧។

[62] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧។

[63] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤។

ទាំងពីររូបបានកត់សម្គាល់ឃើញថា ការចងចាំរយៈពេលខ្លីអាចធ្លាក់ចុះដោយសារតែវាជាផ្នែកមួយនៃដំណាក់កាលជរាភាព ដែលជារឿងធម្មតានោះ[64]។ ហេតុដូច្នេះ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រសន្និដ្ឋានថា ជនជាប់ចោទមិនមានបញ្ហាផ្លូវចិត្ត និងបញ្ហាផ្លូវកាយដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពភាពរបស់គាត់ក្នុងការប្រើប្រាស់សមត្ថភាពទាំងឡាយចាំបាច់ ដើម្បីឆ្លើយតបទៅនឹងបទចោទ និងការចូលរួមក្នុងសវនាការនោះទេ[65]។

## ៥.២. ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសម្បទារបស់ នួន ជា ដើម្បីចូលរួមក្នុងសវនាការ

20. អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជំងឺផ្លូវកាយដែលជនជាប់ចោទបានទទួលរងនេះរួមទាំងការចុះខ្សោយការចងចាំ និងការផ្លង់អារម្មណ៍ ពិតជាមិនអាចរារាំងជនជាប់ចោទមិនឱ្យចូលរួមប្រកបដោយអត្ថន័យ ក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះឡើយ។

21. ជំងឺផ្លូវកាយជាប្រចាំរបស់ជនជាប់ចោទរួមមាន ជំងឺបេះដូង និងបញ្ហាឆ្អឹងខ្នងដែលចេះតែដុនដាបទៅៗ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទបានទទួលរងឧបសគ្គទាំងនេះចាប់តាំងពីសហចៅក្រមស៊ើបអង្កេតបានចាប់ខ្លួនគាត់ដំបូងក្នុងឆ្នាំ ២០០៧ មកម្ល៉េះ[66]។ អ្នកជំនាញវេជ្ជសាស្ត្របានសន្និដ្ឋានថា ជំងឺសរសៃឈាមបេះដូងរបស់ជនជាប់ចោទស្ថិតក្នុងស្ថានភាពមិនប្រែប្រួលទេ ហើយសព្វថ្ងៃបានទទួលថ្នាំព្យាបាលយ៉ាងល្អបំផុត[67]។ អ្នកជំនាញក៏បានសន្និដ្ឋានផងដែរថា បញ្ហាឆ្អឹងខ្នងដែលមានជាយូរមកហើយនេះ ត្រូវបានត្រួតពិនិត្យយ៉ាងល្អបំផុត តាមរយៈការរៀបចំទីកន្លែង ការទ្រទប់ខ្នងផ្នែកខាងក្រោម និងតាមរយៈថ្នាំបន្ថយការឈឺចាប់[68]។ អង្គជំនុំជម្រះពិចារណាឃើញថា វិធានការអនុវត្តជាក់ស្តែងទាំងនេះអាចជួយបន្ថយផលប៉ះពាល់ចម្បងៗ ដែលបណ្តាលមកពីកត្តាទាំងឡាយទៅលើសមត្ថភាពរបស់ជនជាប់ចោទ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងមកលើរូបគាត់។

---

[64] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៨ ដល់ ៣២។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ៥២-៥៣។

[65] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៨។

[66] របាយការណ៍របស់វេជ្ជបណ្ឌិត ឆ្លើយតបទៅនឹងអនុស្សរណៈផ្ទៃក្នុងស្តីពីសុខភាពរបស់ជនជាប់ចោទ ឯកសារ A38/I ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៧។

[67] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩ និងកថាខណ្ឌ ១៨។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២៣។

[68] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១២ និងកថាខណ្ឌ ៤៩។

22. ទោះបីជាការចាប់ផ្តើមជំងឺឡើងបាយភ្នែកទាំងសងខាងនឹងធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់ជនជាប់ចោទក្នុងការអានឯកសារច្បាប់ និងឯកសារភស្តុតាងយ៉ាងណាក៏ដោយ ក៏មេធាវីរបស់គាត់អាចជួយសម្រួលដល់ការប៉ះពាល់នៃការចុះអន់ថយនេះ តាមរយៈការពន្យល់បញ្ហាច្បាប់ដល់កូនក្តីរបស់ខ្លួន និងការអានឯកសារទាំងឡាយឲ្យគាត់ស្តាប់ នៅពេលណាដែលចាំបាច់[69]។ រយៈកាលកន្លងមក ចំពោះការត្អូញត្អែរអំពីបញ្ហាវិលមុខ គឺបណ្តាលមកការមើលមិនច្បាស់នៅពេលគាត់អាន ដោយសារតែជំងឺឡើងបាយភ្នែករបស់គាត់។ ការផ្តល់ជំនួយពីសំណាក់មេធាវីក្នុងការអានឯកសារទាំងនេះ អាចជួយសម្រាលដល់ការចុះខ្សោយនេះបាន[70]។

23. ពាក់ព័ន្ធនឹងការបញ្ជូនជនជាប់ចោទទៅមន្ទីរពេទ្យដោយសារតែការរលាកទងសួត អ្នកជំនាញវេជ្ជសាស្ត្របានរកឃើញថាមិនមានរោគសញ្ញាណាមួយពីជំងឺរលាកសួតនោះទេ ហើយការរវើរវាយបណ្តោះអាសន្នដែលបណ្តាលមកពីការរលាកទងសួត បានជាសះស្បើយរួចទៅហើយដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាថាជំងឺដែលតម្រូវឲ្យជនជាប់ចោទត្រូវចូលព្យាបាលនៅក្នុងមន្ទីរពេទ្យនោះ មិនប៉ះពាល់ដល់សមត្ថភាពរបស់ជនជាប់ចោទនៅពេលនេះទេ។

24. ការចងចាំ និងលទ្ធភាពក្នុងការផ្តង់អារម្មណ៍របស់ជនជាប់ចោទ គឺជាកត្តាដែលពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់គាត់ក្នុងការណែនាំដល់មេធាវីការពារក្តី ក៏ដូចជាសមត្ថភាពក្នុងការផ្តល់សក្ខីកម្ម ក្នុងចំណោមសមត្ថភាពដទៃទៀត។ អង្គជំនុំជម្រះពិចារណាថា ដើម្បីឲ្យជនជាប់ចោទអាចណែនាំដោយត្រឹមត្រូវដល់មេធាវីរបស់ខ្លួនបាន ជនជាប់ចោទត្រូវតែមានការចងចាំរយៈពេលវែង និងការចងចាំរយៈពេលខ្លីគ្រប់គ្រាន់ ដើម្បីរំឭកឡើងវិញពីព្រឹត្តិការណ៍ក្នុងពេលដែលមានការប្រព្រឹត្តិបទឧក្រិដ្ឋដែលរងការចោទប្រកាន់នោះ ព្រមទាំងដើម្បីអាចបញ្ចេញមតិយោបល់ទៅលើភស្តុតាងដែលបានដាក់បង្ហាញ។ អ្នកជំនាញវេជ្ជសាស្ត្របានរកឃើញថាជនជាប់ចោទមានការចងចាំរយៈពេលវែងល្អ ប៉ុន្តែគាត់បានរអ៊ូថាការចងចាំរយៈពេលខ្លីរបស់គាត់រងការធ្លាក់ចុះជាលំដាប់[71]។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ជនជាប់ចោទនៅតែអាចទទួលបានពិន្ទុ ២៨ លើ ៣០ ក្នុងការធ្វើតេស្ត៍ MMSE ហើយគាត់ធ្វើបានល្អចំពោះតេស្តិ៍ពីរដទៃទៀតដែល

---

[69] សេចក្តីសម្រេចលើរឿងក្តី *Strugar* កថាខណ្ឌ ២២។

[70] របាយការណ៍របស់អ្នកជំនាញ ចុះខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១១ និងកថាខណ្ឌ ៣៣។

[71] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧។

រៀបចំឡើងដើម្បីពិនិត្យមើលលើសមត្ថភាពសតិបញ្ញារបស់ជនជាប់ចោទ[72]។ អ្នកជំនាញបានរកឃើញជារួមថា ការចងចាំរយៈពេលខ្លី និងការយកចិត្តទុកដាក់របស់ជនជាប់ចោទនៅរក្សាបាន ហើយគាត់ដឹងពីទីតាំង និងពេលវេលាដែលគាត់កំពុងស្ថិតនៅ[73]។ បន្ថែមពីលើនេះទៀត អ្នកជំនាញវេជ្ជសាស្ត្របានចោទសួរសំណួរលម្អិតមួយចំនួន ដើម្បីពិនិត្យមើលលើការចងចាំរយៈពេលវែងរបស់ជនជាប់ចោទ ហើយជនជាប់ចោទបានឆ្លើយតបនូវចម្លើយដែលមានភាពស៊ីសង្វាក់គ្នា[74]។ ទោះបីជាអ្នកជំនាញកត់សម្គាល់ឃើញថា ការវិវឌ្ឍដោយវ័យចំណាស់តាមលក្ខណៈធម្មជាតិ អាចបន្ថយសមត្ថភាពរបស់បុគ្គលក្នុងការចងចាំនូវព្រឹត្តិការណ៍នានាក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាឃើញថាជនជាប់ចោទមិនបាត់បង់ការចងចាំរយៈពេលវែង ឬ រយៈពេលខ្លីនោះទេ និងបញ្ហានេះមិនធ្វើឱ្យគាត់អសមត្ថភាពក្នុងការចូលរួមការការពារខ្លួនគាត់នោះឡើយ។

25. ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ មេធាវីការពារក្តីបានលើកឡើងជាច្រើនដងនូវទឡ្ហីករណ៍ដែលថាជនជាប់ចោទមិនបានចូលរួមដោយសកម្មភាពក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនោះឡើយ ដោយសារតែជនជាប់ចោទមិនអាចផ្តង់អារម្មណ៍បាន ហើយគាត់ក៏សម្រាន្តលក់ទៅ[75]។ ក៏ប៉ុន្តែ នៅក្នុងរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ អ្នកជំនាញបានរកឃើញថាជនជាប់ចោទមិនមានបញ្ហាគួរឱ្យកត់សម្គាល់ណាមួយទាក់ទងទៅនឹងការផ្តង់អារម្មណ៍ ឬការយកចិត្តទុកដាក់នោះឡើយ[76]។ អ្នកជំនាញវេជ្ជសាស្ត្របានរកឃើញថាជនជាប់ចោទអាចផ្តង់អារម្មណ៍បានរហូតដល់រយៈពេលពីរ

---

[72] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៤។

[73] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៥។

[74] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៨-៣២។

[75] ប្រតិចារិក, 12 មករា 2012, ទំព័រ 55; ប្រតិចារិក, 16 មករា 2012, ទំព័រ 113-114; ប្រតិចារិក, 18 មករា 2012, ទំព័រ 78; ប្រតិចារិក, 14 មីនា 2012, ទំព័រ 112-116; ប្រតិចារិក, 15 មីនា 2012, ទំព័រ 49-65; ប្រតិចារិក, 21 មីនា 2012, ទំព័រ 7-8; ប្រតិចារិក, 18 កក្កដា 2012, ទំព័រ 74; ប្រតិចារិក, 26 កក្កដា 2012, ទំព័រ 52, 55; ប្រតិចារិក, 31 កក្កដា 2012, ទំព័រ 50-51; ប្រតិចារិក, 23 វិច្ឆិកា 2012, ទំព័រ 64-65; ប្រតិចារិក. 5 ធ្នូ 2012, ទំព័រ 39-40; *សូមមើលផងដែរ,* ប្រតិចារិក, 16 កុម្ភៈ 2012, ទំព័រ 4។

[76] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៩។

ម៉ោង ក្នុងមួយពេល ហើយជនជាប់ចោទមិនមានអាការៈអស់កម្លាំងគួរឱ្យកត់សម្គាល់ ព្រម ទាំងរវៀសរវៃរហូតក្នុងពេលដែលអ្នកជំនាញបានធ្វើការសម្ភាសរូបគាត់[77]។ អង្គជំនុំជម្រះពិចារណាឃើញថា ជនជាប់ចោទមិនមានបញ្ហាលើសមត្ថភាពនៃការផ្ចង់អារម្មណ៍នោះទេ។

26. មេធាវីការពារក្ដីបានស្នើដល់អង្គជំនុំជម្រះ ឱ្យបង្គាប់ឱ្យមានការពិនិត្យបន្ថែមលើផ្នែករាងកាយ និងសតិបញ្ញា មុនពេលសម្រេចថា ជនជាប់ចោទមាន ឬមិនមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ប៉ុន្តែមេធាវីការពារក្ដីមិនបានបង្ហាញថាតើការពិនិត្យជាក់លាក់ណាមួយ ឬផ្នែកជាក់លាក់ណាមួយដែលអ្នកជំនាញវេជ្ជសាស្ត្រមិនបានត្រួតពិនិត្យឱ្យបានត្រឹមត្រូវនោះទេ។ អង្គជំនុំជម្រះយល់ស្របជាមួយអ្នកជំនាញវេជ្ជសាស្ត្រថា មិនចាំបាច់ឱ្យមានការពិនិត្យបន្ថែមទៀតនោះឡើយ។

27. ជារួម ដោយផ្អែកទៅលើរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ព្រមទាំងសក្ខីកម្មដែលផ្ដល់ដោយអ្នកជំនាញវេជ្ជសាស្ត្រនោះ អង្គជំនុំជម្រះសម្រេចថាជនជាប់ចោទមានសមត្ថភាពឆ្លើយតបនឹងបទចោទ យល់ដឹងពីលក្ខណៈនៃបទចោទ យល់ដឹងពីកិច្ចដំណើរការនីតិវិធីសវនាការ យល់ដឹងពីភាពពលម្អិតនៃភ័ស្តុតាង យល់ដឹងពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធីសវនាការ យល់ដឹងពីភាពពលម្អិតនៃភ័ស្តុតាង និងផ្ដល់សក្ខីកម្ម[78]។ ជនជាប់ចោទ មានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ហើយវិធានការជាក់ស្ដែងមួយចំនួនដូចបានបញ្ជាក់ខាងលើ គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ផ្នែកសុខភាពរបស់ជនជាប់ចោទ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថាជនជាប់ចោទនៅតែមានកាយសម្បទា និង បញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

## ៥.៣. វិធីនៃការចូលរួមរបស់ជនជាប់ចោទក្នុងសវនាការ

28. អង្គជំនុំជម្រះយល់ស្របថាគួរតែមានការព្យាយាមដោយសមហេតុផល ក្នុងការជួយសម្រាលដល់ការឈឺចាប់ផ្នែករាងកាយរបស់ជនជាប់ចោទ ដើម្បីឱ្យជនជាប់ចោទអាចចូលរួមក្នុងសវនាការ។ ទោះបីជាយ៉ាងនេះក៏ដោយ អ្នកជំនាញវេជ្ជសាស្ត្ររកឃើញថា មិនមានមូលហេតុ

---

[77] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦, ៤១, ៤៩។

[78] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៨-៤៥។

ខាងវេជ្ជសាស្ត្រដែលអាចរារាំងមិនឱ្យជនជាប់ចោទ អាចចូលរួមក្នុងកិច្ចដំណើការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនោះឡើយ[79]។ បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការដែលមានភ្ជាប់ឧបករណ៍ជាពិសេស រួមមានឧបករណ៍សោតទស្សន៍ដែលអាចបញ្ជូនរូបភាព និងសម្លេងកិច្ចដំណើរការនីតិវិធីសវនាការដោយផ្ទាល់ ព្រមទាំងមានខ្សែទូរស័ព្ទសម្រាប់ជនជាប់ចោទអាចទំនាក់ទំនងដោយសេរី និងដោយសម្ងាត់ជាមួយមេធាវីការពារក្តីរបស់ខ្លួន ហើយនឹងមានគ្រែដែលអាចកែសម្រួលបាន ដែលរៀបចំឡើងជាពិសេសសម្រាប់សម្រួលដល់ស្ថានភាពរាងកាយរបស់ជនជាប់ចោទ។ លើសពីនេះទៅទៀត ដោយសារតែបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការស្ថិតនៅក្នុងអគារសាលសវនាការរបស់ អ.វ.ត.ក ទើបក្រុមការពារក្តីរបស់ជនជាប់ចោទមានលទ្ធភាពក្នុងការជួបជាមួយជនជាប់ចោទពេញមួយថ្ងៃ[80]។ ដោយផ្អែកទៅលើការពិចារណាទាំងអស់នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ជនជាប់ចោទត្រូវចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ឬនៅក្នុងសាលសវនាការ។ ហេតុដូច្នេះ សំណើសុំចូលរួមកិច្ចដំណើរការនីតិវិធីសវនាការពីមន្ទីរឃុំឃាំងត្រូវបដិសេធ។

29. លើសពីនេះទៅទៀត អ្នកជំនាញវេជ្ជសាស្ត្ររកមិនឃើញមូលហេតុ ដែលអាចឱ្យពួកគាត់ផ្តល់អនុសាសន៍ឱ្យមានការកែប្រែពេលវេលាសវនាការបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងរក្សាពេលវេលាសវនាការឱ្យនៅដដែល គឺចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង ៩ព្រឹក ដល់ម៉ោង ៤រសៀល ដោយមានការឈប់សម្រាកច្រើនដងក្នុងមួយថ្ងៃ[81]។

30. អង្គជំនុំជម្រះបានដឹងពីស្ថានភាពសុខភាពផ្នែករាងកាយ ដែលមិនទៀតទាត់របស់ជនជាប់ចោទដែលអ្នកជំនាញវេជ្ជសាស្ត្របានពណ៌នាថាជនជាប់ចោទមានសភាពទន់ខ្សោយ។ របាយការណ៍វេជ្ជសាស្ត្របានបញ្ជាក់យ៉ាងច្បាស់ថាស្ថានភាពបច្ចុប្បន្នរបស់ជនជាប់ចោទ អនុញ្ញាតឱ្យគាត់

---

[79] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១៦,៥០។

[80] សេចក្តីសម្រេចលើសម្បទារបស់ អៀង សារី កថាខណ្ឌ ២១។

[81] របាយការណ៍អ្នកជំនាញ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៩។

អាចបន្តការចូលរួមរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ។ ហេតុដូច្នេះ អង្គជំនុំជម្រះ បង្គាប់ឱ្យបន្តកិច្ចដំណើរការនីតិវិធីក្នុងពេលឆាប់ៗ ដើម្បីគាំពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ឆាប់រហ័ស និង ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ កាលណាអង្គជំនុំជម្រះអាចចេញសាលាក្រមក្នុងសំណុំរឿង ០០២ នេះបានទាន់ពេលវេលា។

**ផ្អែកលើសំអាងហេតុដូចបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច÷**

**តម្កល់** ការសម្រេចលើកមុនរបស់ខ្លួន ដែលសម្រេចថាជនជាប់ចោទ នួន ជា មានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យក្នុងការការពារខ្លួនគាត់ ដែលហេតុដូច្នេះហើយទើបជនជាប់ចោទមានកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

**បដិសេធ** សំណើមេធាវីការពារក្តីសុំឱ្យមានការបង្គាប់ឱ្យធ្វើការពិនិត្យបន្ថែមផ្នែករាងកាយ និងសតិបញ្ញាស្មារតី ដល់ជនជាប់ចោទ

**បដិសេធ** សំណើមេធាវីការពារក្តីសុំអនុញ្ញាតឱ្យជនជាប់ចោទអាចចូលរួមកិច្ចដំណើរការនីតិវិធីសវនាការពីមន្ទីរឃុំឃាំង និង

**បង្គាប់** ដល់អង្គភាពពេទ្យ និងមន្ទីរឃុំឃាំង អ.វ.ត.ក ដោយមានជំនួយពីការិយាល័យរដ្ឋបាល អនុវត្តនូវអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រដូចដែលមានក្នុងកថាខណ្ឌ ១៧, ១៩, ២០ និង ២១ នៃរបាយការណ៍អ្នកជំនាញ ខែ មីនា ឆ្នាំ ២០១៣។

ភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន